# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ០៧ ក.ធ.ស ស.រ.ណ.ន

## សេចក្តីណែនាំ

## ស្តីពីការគោរពប្រតិបត្តិសាសនាគ្រីស្ទលើការងារអប់រំក្រៅប្រព័ន្ធ

**យោង:** -រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី១ អធិបតេយ្យភាព មាត្រា១វាក្យខ័ណ្ឌទី២ ព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍មិនចូលបក្សសម្ព័ន្ធ ។ ហើយជំពូកទី៣ មាត្រា ៣១ វាក្យខ័ណ្ឌ ២ " ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់មានសិទ្ធិសេរីភាព និង ករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ " និងមាត្រា ៤៣ "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ " ។

-អនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា ។

-អនុក្រឹត្យលេខ ១៦៨ អនក្រ.តត ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២ ស្តីពីការរៀបចំសមាសភាពគណៈកម្មការជាតិអប់រំសំរាប់ទាំងអស់គ្នា ។

ក្រសួងធម្មការ និងសាសនា មានចំណាប់អារម្មណ៍ទៅលើសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ដែលកន្លងមកដល់បច្ចុប្បន្ននេះ ដែលអង្គការសមាគមក្រុមប្រឹក្សាសម្ព័ន្ធ សហព័ន្ធ និងព្រះវិហារឯករាជ្យនានា ដែលមានចរិតជាសាសនាគ្រីស្ទ ដូចដែលលិខិតស្រាយបំភ្លឺរបស់ឯកឧត្តមរដ្ឋមន្ត្រីស្តីទី លេខពិសេស ដែលបានផ្ទេរសិទ្ធិដោយរដ្ឋមន្ត្រី លេខ ៨១២ ក.ធ.ស ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០២ ពាក់ព័ន្ធទៅនឹងនិកាយប្រូតេស្តង់ខ្លះនោះបានបង្កឡើងហើយ តែងកើតមានជាញឹកញូយ ដូចជាអំពើបំពានជំនឿសាសនារបស់ប្រជាពលរដ្ឋ, អំពើញុះញង់ប្រជាពលរដ្ឋខ្មែរឱ្យស្អប់វត្តអារាម ភិក្ខុសង្ឃ និងពុទ្ធសាសនា, អំពើអុចអាលប្រជាជនឱ្យបោះបង់ជំនឿសាសនាមួយទៅជឿសាសនាមួយទៀត តាមរយៈការផ្តល់សំភារៈលុយកាក់ ។ល។ ទាំងនេះគឺជាអំពើបំពានសិទ្ធិសេរីភាពជំនឿ ដែលមិនអាចអត់ឱន និងទុកឱ្យបន្តកើតមានតទៅទៀតបានឡើយ ។ ហើយម្យ៉ាងវិញទៀតសារាចរណែនាំស្តីពីការងារគ្រប់គ្រងកិច្ចការពាហិរ សាសនា លេខ ០១ ក.ធ.ស. ស.រ.ណ.ន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៣ ដែលអង្គការ សមាគម ក្រុមប្រឹក្សា សម្ព័ន្ធ សហព័ន្ធ និងព្រះវិហារឯករាជ្យ ដែលមានចរិតជាសាសនាគ្រីស្ទមិនបានគោរពទាល់តែសោះថែមទាំងបង្កឱ្យមានភាពអសកម្មមិនគោរពតាមស្មារតីនៃសារាចរនេះ ។

អាស្រ័យហេតុនេះ ក្រសួងធម្មការ និងសាសនា ដែលមានរូបខ្ញុំផ្ទាល់មានតួនាទីគ្រប់គ្រងការងារអប់រំសិក្សាក្រៅប្រព័ន្ធ យល់ឃើញ និងសំណូមពរដល់គ្រប់សាលាខេត្តក្រុង, គ្រប់មន្ទីរធម្មការ និង សាសនាខេត្តក្រុង, គ្រប់ស្ថាប័នអង្គភាពដែលមានការពាក់ព័ន្ធនេះ ត្រូវសហការឱ្យបានល្អក្នុងករណីខាងលើនេះ, មេត្តាយកចិត្តទុកដាក់ និងគ្តាប់ឱ្យបានក្នុងការរួមចំណែកធានាឱ្យបាននូវការងារសណ្តាប់ធ្នាប់,សន្តិសុខសង្គម,ប្រឆាំងនិងគ្រប់មុខសញ្ញាភេរវកម្ម ដែលប្រទេសមួយចំនួននៅក្នុងបណ្តាប្រទេសអាស៊ានយើងមានបានជួបប្រទះរួចមកហើយនូវសកម្មភាពភេរវកម្មជ្រុលនិយមនេះ ។ ហើយម្យ៉ាងទៀតមានជនជាតិបរទេសមួយចំនួន ដែលមកបំពេញភារកិច្ចជាអង្គការមនុស្សធម៌មិនមែនរដ្ឋាភិបាល ដោយបានចុះអនុស្សរណៈនិងរាជរដ្ឋាភិបាលតាមរយៈក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិបានបំពានតួនាទីភារកិច្ចរបស់ខ្លួនមកជាបេសកកម្មសាសនាគ្រីស្ទ បង្រៀនអប់រំក្រៅប្រព័ន្ធស្នាក់អាស្រ័យនៅក្នុងវិហារ ឬការិយាល័យសាសនាគ្រីស្ទរបស់ខ្លួនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជាតិ និងសណ្តាប់ធ្នាប់សន្តិសុខសង្គម ហើយមិនបានគោរពនូវសេចក្តីណែនាំ លេខ ៨៦២/៩៤ ក.ធ.ស.ន.ស ចុះថ្ងៃទី ១២ ខែ១០ ឆ្នាំ ១៩៩៤ របស់ក្រសួងធម្មការនិង សាសនា ។

ដូចនេះ ក្រសួងមិនឯកភាពចំពោះការងារអប់រំក្រៅប្រព័ន្ធរបស់អង្គការ សមាគម ក្រុមប្រឹក្សា សម្ព័ន្ធ សហព័ន្ធ និងព្រះវិហារឯករាជ្យនានា ដែលមានចរិតជាសាសនាគ្រីស្ទទាំងនោះដូចដែលបានរៀបរាប់ខាងលើ និង សូមអំពាវនាវដើម្បីផលប្រយោជន៍ជាតិសណ្តាប់ធ្នាប់និងសន្តិសុខសង្គម សូមគ្រប់សាលាខេត្ត-ក្រុង គ្រប់មន្ទីរធម្មការ និងសាសនាខេត្ត-ក្រុង មេត្តាផ្សព្វផ្សាយធ្វើយ៉ាងណាឱ្យអង្គការសមាគមក្រុមប្រឹក្សាសម្ព័ន្ធ សហព័ន្ធ និងព្រះវិហារ ឯករាជ្យនានា ដែលមានចរិត ជាសាសនាគ្រីស្ទគោរពឱ្យបាននូវសារាចរ សេចក្តីណែនាំ និងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ជាពិសេសក្រសួងធម្មការ និងសាសនានៃព្រះរាជាណាចក្រកម្ពុជាយើង ។

ភ្នំពេញ ថ្ងៃទី០២ ខែ តុលា ឆ្នាំ ២០០៣

ក្រសួងធម្មការ និងសាសនា

រដ្ឋលេខាធិការ

ឌោក ណារិន

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

" ដើម្បីគោរពជូនជ្រាប "

- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់មន្ទីរធម្មការ និងសាសនាខេត្ត-ក្រុង
- គ្រប់ក្រុមប្រឹក្សាគ្រីស្ទ
- គ្រប់ព្រះវិហារ កន្លែងថ្វាយបង្គំរបស់សាសនាគ្រីស្ទ

" ដើម្បីមុខការ "

- ឯកសារ-កាលប្បវត្តិ